* មេព័ន្ធតាលឹង

* ក្បាច់ពន្រ្ទួលត្បូលដី លូនបំបែកក្លូង




-ក្បិនក្រហម ទាត់កាត់ក្រឡាច ។

-ក្បិនខៀវផតផុត រុក ជើងស្តាំចូលរបៀបសន្ទុះឥន្ទ្រី បុកជើងស្តាំចូលពីក្រោយ ជើងដែលទាត់ ជើងឆ្វេង ទាត់ចូលគន្លាក់ជើង ក្បិនក្រហម ស្របនឹងដៃរង ក្បិនក្រហមដួលផ្ងារបាក់ជើង ។ បុរាណខ្មែរឱ្យឈ្មោះ ថា "ស្ទិលត្បូលដី" ។

* មេភាត់គងថ្ងៃព្រះអាទិត្យ

* ក្បាច់ខ្លែងហែកចំណី

* កណ្ដាប់ដៃក្រញាំខ្លែង

-ក្បិនក្រហម ដាល់បុកដៃទាំងពីរ សំដៅចុងដង្ហើម ក្បិនខៀវ ។ ក្បិនខៀវ យកជើងទាត់គាស់ភ្លៅស្រប នឹងដៃទាំងពីរផ្ទក់ កដៃទាំងពីររបស់ក្បិនក្រហម ហើយហែកពីក្នុងចេញក្រៅ លោតជើងស្តាំទាត់ធាក់ បំពង់ក ។ បុរាណខ្មែរឱ្យឈ្មោះថា "ឥន្ទ្រីហែកចំណី" ។



### ✻ មេកែងនេះ



### ✻ ក្បាច់ជង្គង់ហោះពុះដូង ឬខ្លែងក្រុងកូនមាន់

-ក្បិនខៀវប្រើហក់ចុចចុងជើង ជាន់ភ្លៅក្បិនក្រហម ប្រើកែងទាំងពីរគប់ចំពីលើ និងរុញបញ្ចិតចេញក្រៅក្បាច់នេះខ្លះហៅថា "ក្បាច់ពុះដូង" ខ្លះហៅថា "ក្បាច់ ខ្លែងក្រុងកូនមាន់" ។

ឯក្បិនក្រហម ប្រើក្បាច់ទ្រផ្កា ប្រើកណ្ដាប់ដៃ ទាំងពីរ បុកត្រង់ឡើងលើ រះទៅចង្កា ពីដើមទ្រូងឡើងលើ ។ ខ្លះហៅថា "ក្បាច់បុកចន្លុះ" ។



### ✻ មេផាត់អុកអង្រែ

### ✻ ក្បាច់ផ្កាស្វាយរីក

- គូម្ខាង ប្រើមេផាត់ក្រៅ គឺយកដៃផាត់ខ្វែងពីក្រោយ រួចយកដៃស្រប គប់កែងដៃត្រង់ គល់ភ្លៅអ្នកទាត់ រួចឱបឡើប រុញគ្រវែងជើងអ្នកទាត់ ចោលចេញក្រៅ ក្បាច់នេះឈ្មោះថា "មេផាត់អុកអង្រែ " ។

- អ្នកទាត់ ប្រើជើងទាត់រះយកស្នងជើង ដៃទាំងពីរ វាយសម្រុក ទាំងឆ្វេងទាំងស្ដាំ ពីក្នុងចេញក្រៅ ។ ក្បាច់នេះហៅថា "ក្បាច់ផ្ការីក " ។

*** គុនដៃបំបែកស្នៀតចូល ប្រកួត**

*** ក្បាច់ក្របីព័ន្ធស្នឹង**

*** មេបង្ហាញពល**

*** ក្បាច់ច្រកទទឹង**



- ក្បាច់ទាំងនេះ ពេលប្រកួត ច្រើនប្រើ ទទឹងខ្លួន ជើង វវៀស ប្រើកែងជើង បករក កញ្ចឹង-ក រួចឡើងទាំងជើង ទាំងដៃ ម្ខាងទៀតឡើងទាំង ជង្គង់ ទាំងដៃទៅលើគូប្រកួត ដែលហៅថា "ក្បាច់ក្របីព័ទ្ធ ស្ទឹង មេបង្ហាញពល ឬក្បាច់ ច្រក ទទឹង" ។

*** ប្រកួតគុនដៃ**

*** ក្បាច់ស្រវៃពេន ជាមួយក្បាច់សេះប្រាយ**



*** ក្បាច់ព្យុះក្លួចកន្ទ្រើយ**

- ជំហរក្បិនក្រហមរបៀបសេះ ប្រាយ ឯក្បិនខៀវប្រើក្បាច់ ព្យុះកួចកន្ទ្រើយ ។

*** មេកួចកន្ទ្រើយ** : ដៃចេញ ក្ដាប់មូរបង្វិលពីក្នុងចេញក្រៅ ។

*** សេះប្រាយ:** ដៃមូរបង្វិលខ្លួន ធាក់ច្រត់ឥសី "ធាក់កែងជើង ទៅក្រោយ ធាក់យកចុងដង្ហើម រះទៅចង្កា" ។

✻ សម្តែងឫទ្ធិ រំលឹក គុណគ្រូ

✻ បើកមេទ្វារប្រាំបី នាងនាគក្រៃកដី



✻ ស្លៀតវាយលុក

✻ ក្បាច់ខ្លាទះ ទប់ទល់ជាមួយក្បាច់មហារំអិល




- ក្បិនខៀវប្រើក្បាច់ខ្លាទះលោតចំពីមុខ ។

-ក្បិនក្រហម យកដៃជ្រោងកៀសចេញក្រៅ ញែកពីក្នុងដាល់សើយចង្កាក្បិនខៀវ បោះជើងចូលស្ទាំទះបាតជើងអារក្ស ត្រង់ជន្ទល់ក្បិនខៀវឱ្យដួលផ្ងារ ក្រោយ ។

✻ **នេះក្នុងមេគុនខ្លាក្រាប** ។

✳ មេកែងឆេះ

✳ ក្បាច់ជន្លង់ហោះពុះដូង




-ក្បិនខៀវ លោតជាន់ឡើង អុកកែង ស្របនឹងជង្គង់ស្តាំ បុកទ្រូងក្បិនក្រហម ។

-មួយមេគុននេះ បុរាណខ្មែរឱ្យឈ្មោះថា "ហនុមានទូងស្គរ" ។



✳ មេបីដៃ

✳ ក្បាច់វាយអុកមេពីរ កាត់បុកចំហៀង បំបែកក្នុង

- មេនេះឈ្មោះថា "មេបីដៃ" គឺវាយម្តងបីដៃជាប់ៗគ្នា មានវាយលើផាត់ក្រោមដល់លើ ។

- ដៃគូម្ខាងឡើងជង្គង់បត់ បុកចំកណ្តៀតក្អម ប្រើដៃទាំងពីរវាយសង្គ្រប់លុកមេពីរ ដៃម្ខាងកាត់ដៃម្ខាងវាយបុកចំហៀងបំបែកចេញពីក្នុង ដែលបុរាណខ្មែរឱ្យ ឈ្មោះថា "មេលុកបំបែកក្នុង" "ធីតាសួគ៌ា" ។

✲ ដេញមេ

✲ ចូលប្រយុទ្ធ

✲ ក្បាច់បំបើុងធរណី ទប់ទល់ជំហានរាជសីហ៍

-ក្បិនក្រហមប្រើក្បាច់បំប៉ើងធរណី ។ ក្បាច់នេះប្រើច្រើនមូរដៃ បុកពីក្រោមឡើងលើ ដែលជាក្បាច់ពិបាកទប់ទល់ណាស់ ព្រោះទាំងដៃ ទាំងជំហានសុទ្ធតែដូចបញ្ឆោត ទាំងអស់ ។





✲ ក្បាច់ទ្វារប្រាំបីសង្គ្រប់នាគព័ន្ធ

-ក្បិនក្រហមប្រើក្បាច់នាគព័ន្ធទប់ជង្គង់ ។
-ក្បិនខៀវដែលទាត់ បត់ជង្គង់និងកែង ។ ជើងក្បិនក្រហមឡើងទាត់ផ្ដួលជើង ក្បិនខៀវ និងដៃ ក្បិនក្រហម បង្វិលកាច់ បោកដៃក្បិនខៀវឱ្យដួល ។

### ✻ ក្បាច់ហង្សបំបែកសំបុកឆប់ក្បាច់ ផ្ការោយ

- ក្បិនខៀវសម្រុកចូល ទាត់ផង ដាល់ផងតាមក្បាច់ ផ្ការោយ ។

- ក្បិនក្រហមយកដៃគប់ជង្គង់ ដោយប្រើដៃឆ្វេង ឯដៃស្តាំដាល់ចូលក្បាលពោះ ក្បិនខៀវ តាមក្បាច់ហង្សបំបែកសំបុក ។

ក្បាច់នេះ ប្រើស្នៀតទាប បុកឆ្កឹះឡើងលើ ។





### ✻ ក្បាច់បំភ័ន្តស្នៀតចូលប្រកួត

### ✻ មេជ្រែកធរណី

- ក្បាច់នេះជាក្បាច់បញ្ឆោតត្រៀមចូលប្រយុទ្ធ មាននៅក្នុងមេគុន ព្រះរាមចូលកោដិបញ្ឆោតនាងសីតា គឺប្រើជំហរពាក់កណ្តាលខ្លួន បន្ទាបចុះក្រោម ឈ្មោះថា "មេក្បាច់ជ្រែកធរណី" ។

### * ក្បាច់រាហ៊ូទល់មេឃ ទប់ក្បាច់ខ្លាឆ្លងស្ពាន



- ក្បិនក្រហមប្រើក្បាច់រាហ៊ូទល់មេឃ គឺយកដៃឆ្វេងរងកាត់ ដៃឆ្វេងដូចគ្នា ដែលក្បិនខៀវ វាយសំរុកចូលរុញឡើងទល់ទៅលើ ។

* ក្បិនខៀវ គងដៃឆ្វេងកាត់មេខ្វែងស្រប ទម្លាក់ដៃឆ្វេងក្បិនក្រហមចុះ រួចដកដៃស្តាំវាយចូលចំចំណុចទិសដៅ កៀសដៃស្តាំដែលក្បិនខៀវ បញ្ចេញ បុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ខ្លាឆ្លងស្ពាន" ។

### * ក្បាច់ព្រះរាមយឺតធ្នូ ទប់ក្បាច់ហែកត្របកផ្កា



- ម្ខាងលើកជើងទាត់ ក្បាច់ព្រះរាមយឺតធ្នូ ម្ខាងប្រើករងទម្ងន់ជើង របៀបមច្ឆាគ្រលែងខ្លួន រួចបុកកែងដៃឆ្វេង ត្រង់គល់ភ្លៅអ្នកទាត់ រួចដកជើងស្តាំ ទាត់ផ្តួលជើងឆ្វេងអ្នកដែលទាត់ នឹងជ្រោងបុកកែងដៃស្តាំ ចំផ្ទៃមុខគូប្រកួតដោយទាត់បង្វិល ចុះក្រោម បុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ទប់ហែកត្របកផ្កា" ។

## * ក្បាច់ជ្រងបំបែកឃុំ ទប់ក្បាច់ខ្លាត្រូវរបួស




- ម្ខាងចងខ្សែក្រហម ប្រើក្បាច់ខ្លាត្រូវរបួសបោះជំហានចំហៀង វាយដៃទាំងសងខាងទៅលើគូប្រកួតដែលដៃមួយឈ្មោះថា "អន្លងហនុមាន និងដៃមួយទៀតហៅថា ឆ្កាមជើងនាគ" ។
- គូម្ខាងទប់ជ្រោងបំប៉ើងឡើងលើ ដៃម្ខាងទៀតត្រៀមបុកបំប៉ើងដើមដៃ និងទប់សងកណ្តាប់ដៃនៃដៃគូ ។ ក្បាច់នេះបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ជ្រងបំបែកឃុំ" ។

## * ក្បាច់អូតូច ទប់ក្បាច់ទងផ្កា



- ក្បិនខៀវប្រើក្បាច់អូតូច ឬឥន្ទ្រីបញ្ចុកចំណី វាយទៅលើក្បិនក្រហម របៀប បាតដៃឥសូ គឺវាយ ឆែកចូលក្នុង ចំថ្គាមក្បិនក្រហម ។
- ក្បិនក្រហមប្រើបាតដៃវាយ របៀបខ្នងដៃឥសូវាយខ្ទប់ដៃក្បិនខៀវ កាត់ វាយចំចំណុចដើមទ្រូង ក្បិនខៀវ ដែលបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ ទងផ្កា" ។

✱ **ក្បាច់សេះប្រាយក្លូង**

✱ **ទប់ក្បាច់កំហឹងនាគ**



- ក្បិនខៀវ ប្រើក្បាច់ជើងសេះប្រាយក្នុង ទាត់បង្វិលពីក្នុងចេញក្រៅ គៀសដៃក្បិនក្រហម បុកជង្គង់តាមក្បាច់ "ជ្រែកពពក" និងជង្គង់ផ្លុចពីក្រោមឡើងលើ បុរាណខ្មែរឱ្យឈ្មោះថា "ហនុមានទប់មេឃ" ។

- ក្បិនក្រហម ប្រើដៃរបៀប "ដាវហនុមាន" វាយកាត់ដៃឆ្វេងក្បិនខៀវ និងដៃស្តាំប្រើកណ្តាប់ដៃរបៀប "ចំពុះសេដាយស់ និងបុកចំដើមទ្រូង ក្បិនខៀវ ឈ្មោះថា "ក្បាច់កំហឹងនាគ" ។

✱ **ក្បាច់ស្វាបៀក ទប់ក្បាច់ផាត់អណ្តែត**



- ក្បិនខៀវ ខ្ទប់ប្រើកែងដៃ របៀប "ឥសីទប់មេឃ ឬ នាគព្រួសពិស" បែបកែងបញ្ឆិតពុះ ពីលើ ញែកចំហៀងបុរាណខ្មែរ ឱ្យឈ្មោះថា "ក្បាច់ស្វាបៀក" ។

- ក្បិនក្រហម ប្រើកែងដៃស្តាំ ទប់កំភួនដៃក្បិនខៀវ ត្រៀម ដៃឆ្វេងដាល់សើយចង្កា ក្បិនខៀវ រួចរុញកែងដៃក្បិនខៀវត្រង់ពីក្រោមទៅលើ ឈ្មោះថា "ក្បាច់ផាត់អណ្តែត" ។

### * ក្បាច់ញែកទី ទប់ក្បាច់ កាត់ជ្រង

- ក្បាច់ទាំងពីរនេះប្រើរបៀប
ឥសីសម្តែងឫទ្ធិ ឬដាវហនុមាន
ដាល់ខ្ទប់ពីឆ្វេងទៅស្តាំ កាត់ដក
ពីឆ្វេងទៅស្តាំទាំងសងខាង ជើង
គាស់ជើងឆ្វេង គាស់ឆ្វេង គាស់
ស្តាំ ដែលឱ្យឈ្មោះថា "ក្បាច់
ញែកទី" ឬ "ក្បាច់កាត់ជ្រង" ។



### * ក្បាច់ទេពប្រណម្យ ទប់ក្បាច់ជ្រំជើងសេះ



- គូម្ខាងប្រើជើងទាត់ខ្នង
ប្រអប់ជើង តម្រង់កញ្ចឹង
-ក គូ ប្រកួត ឬពាក់
កណ្តាលខ្លួន ឈ្មោះថា
"ព្យុះសមុទ្រ" ឬ ជ្រំជើង
សេះ ។ គូម្ខាងប្រើចាប់
ជើងរួចលើកជើងស្តាំទាត់
ជ្រំជើងអារក្ស ខ្ទប់ពីក្រៅ
ចូលក្នុង ឈ្មោះថា "ក្បាច់
ទេពប្រណម្យ" ទប់ជ្រំជើង
សេះ ។

## * ក្បាច់គងអណ្ដែត ទប់ក្បាច់ផាត់សារាយ



- ក្បាច់នេះ ម្ខាងទាត់អង្កុញ ជង្គង់ សម្រុកចូលវាយជង្គង់បត់ និង ពុះកែងដៃ ឈ្មោះថា "ក្បាច់គងអណ្ដែត" ។

- ឯម្ខាង លើកជង្គង់ទប់ពីក្នុងកៀសចេញក្រៅ បម្រុងឡើង ជង្គង់ បត់ជើងម្ខាង រួចវាយកែង ពុះដូងឈ្មោះថា " ក្បាច់ផាត់ សារាយ " ។

- ទ្វារទីប្រាំបី គឺជាទ្វារបញ្ចប់នៃអាស្ល័ណ្ឌយុទ្ធ មាន៥០មេរួម រួចនៅក្នុងមេទ្វារប្រាំបីនេះ គ្មានក្បាច់ គ្មានស្នៀតទេ គឺមានតែមេរួមប៉ុណ្ណោះ ។



# ក្បាច់ប្រកួតដំបងខ្លី

✻ លោកគ្រូ មាស សុខ បង្ហាញក្បាច់រំលឹកគុណគ្រូ បើកដំបងខ្លី ។




✻ ក្បាច់រំលឹកគុណគ្រូ

✻ ជំហរខ្លាធំ

✻ មេគុន ទាំងគុនដៃ គុនដំបងខ្លី-វែង គុនដាវ គុនលំពែង សុទ្ធតែប្រើរំលឹក គុនគ្រូដូចៗគ្នា ។ ប៉ុន្តែគ្រាន់តែស្មៀតនិងមេក្បាច់ខុសៗ គ្នាតែប៉ុណ្ណោះ ព្រោះនេះជាគោលនឹងមេបើកទ្វារប្រកួត ។

## ✻មេស្វាហក់ពាំផ្កា




### -ក្បាច់វាយលុកក្នុង ដោះឆ្វេងស្តាំ

- ក្បាច់នេះគេវាយលុកពីក្នុង ទាំងលើ ទាំងក្រោម ។ ក្រោម វាយយកជើងលើ វាយតម្រង់ក្បាល លុកចូលដេញទៅមុខ ដេញថយក្រោយ ។ ចំណែកអ្នករងក៏ដូចតែគ្នា រងផងវាយដោះផង ដណ្តើមក្នុងដូចគ្នា ។ ប៉ុន្តែការវាយគឺ ហក់ដោះខ្លួន និងវាយលុកតែម្តង ដែលហៅថា "មេស្វា ហក់ពាំផ្កា" ។

**ស្វាហក់ផង វាយផង ទាំងខាំផង ។**




### * មេពី បំបែកឆ្វេងស្តាំ

### * ក្បាច់គោះអង្រែ

- មេនេះប្រើដៃក្រោម វាយតម្រង់ក្បាលជង្គង់បង្វិលចេញក្រៅ ដៃលើវាយលុក ខ្ទប់ចូលក្នុងតម្រង់កញ្ចឹង-ក ។ ឯអ្នករង គឺរងដៃខាងលើ វាយសង្កត់ដំបងចុះក្រោម និងដៃខាងក្រោមវាយផ្ទឹបដំបង ក្រោមចុះដី រួចដៃខាងលើវាយជះចេញវិញ ត្រង់ចំណុចកញ្ចឹង-ក ដូចគ្នា និងដៃខាងក្រោមវាយត្រឡប់ ចេញកាត់ជើងក្រោមដែលគូប្រកួតបោះជំហានចូល ។ ក្បាច់នេះបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់គោះអង្រែ" ។

### * មេមួយបើកប្រកួតពីមុខ

### * ក្បាច់ខ្យល់កួចចំបើង



- មេនេះវាយរហ័សណាស់ ចំពីមុខ វាយកួច បង្វិលកាត់លើវាយក្រោម កាត់ក្រោម វាយលើជើង ហក់បង្វិល របៀបមេព័ន្ធដៃ វាយរុលទៅមុខទៅក្រោយ ។

- ការវាយតម្រង់គ្រប់តួខ្លួន តាំងពីក្បាលរហូត ចុងជើង ដែលបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ខ្យល់កួចចំបើង" ។ ខ្លះហៅថា "ខ្យល់កំបុតត្បូង" ។

### * មេពីរប្រកួតដេញ ចំហៀងក្បាច់អូសបន្លា

- ក្បាច់នេះប្រើរបៀបវាយខ្លះ ចំហៀងចូលផង ទប់ផង ថយផង ។ គេវាយរុលឆ្វេង រុលស្តាំ ទប់ឆ្វេង ទប់ស្តាំ ថយឆ្វេង ថយស្តាំ ចំហៀងដូចគ្នា ។ វាយក្រោម សង្កត់លើ វាយលើ សង្កត់ក្រោមរួចបង្វិលខ្នង វាយទប់ ខ្នងនឹងខ្នង ដេញចំហៀងដូចគ្នា ដែលបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់អូសបន្លា" ។



### * មេមួយ រងស្តាំបំបែកឆ្វេង ដណ្តើមក្លូង ក្បាច់វាយស្គរធំ



- មេនេះ អ្នករងគឺរងដៃស្តាំវាយបំបែកដៃឆ្វេង ចំពីលើវាយដេញពីមុខ រងពីមុខចំ ។ ឯអ្នក វាយគឺវាយលើ រងជាប់ វាយពាក់កណ្តាលខ្លួន ដៃក្រោម គោះក្រោមបោះជើងចូល ដូរ វាយលើ រួចអ្នករង គឺរងវាយដោះដូចគ្នា ។ ក្បាច់នេះបុរាណខ្មែរឱ្យ ឈ្មោះថា "ក្បាច់វាយស្គរធំ" អន្លូងស្គរវាយញាប់ច្រើនដង ដៃហ្លួងបណ្តើរកូន ដៃម្ខាងវាយដករន្ទើន ។

✳ មេពីរទប់លើបុកក្រោម
ក្បាច់បេះចង្រ្កង់ហនុមាន



- ក្បាច់នេះ ក្បិនក្រហម ប្រើទល់ច្រក គឺទប់ទល់ ដំបងដៃលើ បុកច្រកដៃក្រោម ។ ក្បាច់នេះប្រើ ឆ្វេងស្តាំដូរគ្នា ទប់លើ បុកក្រោម ទប់ក្រោម បុកលើ រកកន្លែងចន្លោះ ។ ក្បាច់នេះ ហៅថា "ក្បាច់មេពីរ" ។

- ចំណែកក្បិនខៀវ គឺដេញវាយទៅមុខ ថយក្រោយតាមចង្វាក់ តាមស្នៀតដែលក្បិនក្រហម វាយនិងបុក ។ ក្បាច់នេះ បុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់បេះចង្រ្កង់ហនុមាន" ។

## លោកគ្រូ ឈិន សេន

លោកគ្រូ ឈិន សេន អាយុ ៥០ ឆ្នាំ នៅភូមិតាដឹម ឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។ លោកគ្រូ ស្ទាត់ជំនាញក្បាច់ដើម មេមួយ មេពីរ មេបី ក្បាច់ទ្វារប្រាំបី ខ្លាក្រាប នាគព័ន្ធ ស្រងៃពេន ។ល។

រូបនេះ លោកគ្រូ ប្រើមេសួរឮដំបង លបចូលដំណាក់ ។





### ✻ មេខ្វែងគោះក្រោម វាយល្មុកឈើ

- ក្បាច់រះស្លឹកឈើ

- ក្បាច់នេះប្រើមេខ្វែង គឺវាយខ្វែងគ្នា វាយក្រោម សង្កត់ក្រោម វាយលើរះលើសង្កត់លើ ។ ក្បាច់នេះ ខ្លះហៅថា "ផាត់ញែក ពពក" ។

- ឯខាងក្បិនខៀវ វាយបញ្ច្រាសរះលើក្រោម ឆ្វេងស្តាំ កួចដិបងពីក្រៅចូលក្នុង ។ ក្បាច់នេះបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់រះស្លឹកឈើ" ឬ "ច្រាសស្រកាត្រី" ។

### ✻ មេបំបែកញីឈ្មោល ក្បាច់រងក្នុង ទប់ក្រៅ

- ក្បិនក្រហមប្រើមេបំបែក គឺក្បិនខៀវ វាយជំហានមុខក្បិនក្រហម ។ ក្បិនក្រហមទប់បញ្ច្រាសពីក្នុងចេញក្រៅ ។ ក្បិនខៀវ វាយមូរពីលើ ក្បិនក្រហម រងគាស់ពី (ក្នុងចេញក្រៅ ដូចគ្នា) ។ ក្បាច់នេះបុរាណខ្មែរឱ្យឈ្មោះថា "មេបំបែកញីឈ្មោល" ឬក្បាច់ "បញ្ច្រាសស្រកី" ។ ក្បាច់នេះនៅក្នុងសង្គ្រាមទ្វារប្រាំបី មេប្រាំកាត់យកមេបួន ។



* មេវាយឆ្វាក់ក្នុងក្រៅ
ក្បាច់ខ្លាប្រឡែងចំណី



- ក្បិនខៀវ លបវាយឆ្វាក់ពីក្រោយខ្នង ដោយប្រើមេប្អូនវាយរះបុកមេពីរ ។

- ឯក្បិនក្រហម ប្រើក្បាច់ខ្លាប្រឡែងចំណី គឺវាយទប់រងទាំងពីរ លើក្រោម ងាកវាយកាត់ឆ្វេងស្តាំ បោកទៅមុខ ។ ក្បាច់ខ្លាប្រឡែងចំណីនេះ ប្រើស្មៀតទាប សំខាន់វាយយកជើងក្រោម បំបាក់កជើង ។




* ដំបងខ្លីវាយដេញមេប្អូនលើក្រោម
ក្បាច់ក្រុងអង្រុត

- ក្បាច់នេះម្ខាងវាយក្រោមយកជើង ។ ខាងម្ខាងហក់លើកជើង កាត់ដំបងទប់ក្រោម ។ ខាងម្ខាងវាយលើចំពីមុខ ។ ខាងម្ខាងទៀតវាយកាត់ខ្ចប់ចូលក្នុង ។ ក្បាច់នេះ ប្រើដេញមេប្អូន និងម្ខាងទៀតប្រើក្បាច់ក្រុងអង្រុតវាយទប់កាត់ សង្កត់ក្រុងចុះក្រោម ។

# ក្បាច់ប្រកួតដំបងវែង




### * មេជីងជ្រងវាត់កន្ទុយ

### ក្បាច់ជំហរនាគ

- ក្បាច់នេះឈ្មោះថា "ក្បាច់ជំហរនាគ" គឺវាយឈរត្រង់ ពឹងកម្លាំងត្រង់ពីមុខដូចគ្នា អ្នកវាយក៏ពឹង អ្នករង ក៏ពឹង ។ បុរាណខ្មែរឱ្យឈ្មោះថា "ជីងជ្រងវាត់កន្ទុយ" គឺរងទប់ ស៊កចុះក្រោម ។ ខ្លះហៅថា "ក្បាច់ជំហរនាគ" ។ គេប្រើ ជំហរខ្ពស់ដេញវាយ បុកសើយ នៅតែខ្ពស់ដូចគ្នា ។

### * លោកគ្រូ សារិត អ៊ុង បើកក្បាច់ដំបងវែង



### * មេសើយឈាត់

### ក្បាច់បញ្ឆោតឆ្វេង-ស្តាំ

- មេនេះវាយសុទ្ធតែសើយពី ក្រោមឡើងលើទាំងអស់ ។

### * មេបំបែកស្នៀតដំបងវែង ប្រកួតដណ្ដើមទី ប្រើមេសម

- ក្បាច់នេះក្រោយពីថ្វាយបង្គំគ្រូរួច គូប្រកួតបុកដំបង ទល់គ្នាត្រៀមបំបែកមេ ប្រកួតគ្នាតាម ក្បាច់រៀង៧ខ្លួន ។




### * មេជ្រងរះផ្កាស្វាយ ក្បាច់ជំហរទល់មេឃ



- ការប្រើលក្ខណៈរបៀបនេះឈ្មោះថា "ដំបងចុងពីរ" របៀបប្រើដំបងចុងពីរ វាយទ្រង់ស្រាលបន្តិច ប៉ុន្តែមានភាពរហ័សជាងដំបងចុងមួយ ព្រោះគេប្រើវាយចុង ទាំងសងខាង ទាំងវាយទាំងបុក ។ ឯក្បាច់នេះ បុរាណខ្មែរឱ្យឈ្មោះថា "មេជ្រងរះផ្កាស្វាយ" និងប្រើចុង ដំបងរបៀបជំហរ ទល់មេឃ គឺវាយលើរងលើ បុកក្រោមទប់ក្រោម ។

### * មេផាត់ប្រមូល
### ក្បាច់ទល់ពពក

- របៀបនេះហៅថា ដំបងចុងមួយ ប្រើមេផាត់ប្រមូល មេនេះវាយចំហៀងខាងលើចំ កញ្ចឹង-ក រួចគ្រវីដំបងចុះក្រោម វាយចំពាក់កណ្តាលចង្កេះ ។ ចំណែកឯជើងធាក់ទប់នេះ ឈ្មោះថា ក្បាច់ទល់ពពក គឺទប់ជើង យកចុងដំបងទប់លើ ជ្រោងទល់កុំឱ្យដំបងខាងម្ខាងទៀតវាយដល់ក្បាល ។



### * មេគ្រវីទង់ចាប់បុក
### ក្បាច់ទល់អង្រែ




- ក្បាច់នេះគេប្រើបុកចំពោះឬចំចង្កេះ ដៃម្ខាងចាប់ដំបងដៃគូប្រកួត ពេលដៃគូបុកតម្រង់ជើង គ្រាន់តែដកបន្តិច ដៃចាប់ដំបងជាប់ រួចបុកដំបងទៅចំចង្កេះដៃគូប្រកួត ។

- កន្លែងខ្លះឱ្យឈ្មោះថាក្បាច់ទល់អង្រែ ព្រោះភាពរហ័ស នៃដៃគូម្ខាងអាចបង្វិលដំបងខ្ទប់ទល់គ្នានៅចំពីមុខ រួចដោះរៀងៗខ្លួន ។

## * របៀបចេញមេសើយ លាត់ចេញបញ្ឆោតក្បាច់បទទ្រនងឬក្បាច់ទប់ទឹក

- លំនាំនេះគឺការបើកក្បួន ចេញជំហរប្រកួត របៀបមេ សើយលាត់ គឺវាយសើយពី ក្រោមឡើងលើ ។
- ឯក្បាច់គ្រវីវាយ ឈ្មោះថា ក្បាច់បទ ទ្រនង ឬក្បាច់ទប់ទឹក របៀបយកចបកាប់ដី ទប់ទឹកភ្លឺស្រែ ។ ការវាយបែបនេះពិបាកនឹងទប់ណាស់ ដៃគូ ម្ខាងច្រើនប្រើមេបុកអង្រែ ឬបុកបង្គោលស្ពឹង ទើបទប់ជាប់ ។



# ក្បាច់ដំបងខ្លីប្រកួតដំបងវែង



**✻ ក្បាច់ដណ្តើមសក្តិ ដំបងខ្លីប្រកួតជាមួយដំបងវែង**

✻ ដំបងខ្លីវាយជាមួយដំបងវែង គឺប្រើមេផ្គុំដំបង គឺពេលដំបងវែងវាយចំណុចណាមួយ ខាងដំបងខ្លីយកដំបងទាំងពីរវាយខ្ទប់ចុងដំបងវែង ដោយដកដងខ្លួនឱ្យផុតបន្តិច រួចគោះបញ្ឆោត ដេញវាយដំបងវែង សម្រុកចូលកៀក ដណ្តើមវាយក្នុងក្រៅដែលឱ្យឈ្មោះថា "ក្បាច់ដណ្តើមសក្តិ" ព្រោះដំបងខ្លីដណ្តើមចូលកៀកដំបងវែង ដណ្តើមដោះខ្លួនចេញឆ្ងាយ ។

# ក្បាច់ដំបងវែងប្រកួតគុនកន្សែង



✻ ដំបងវែងប្រើមេចុងពីរ
ក្បាច់ទ្រនុងផ្កាស្វាយ

- កន្សែងប្រើក្បាច់ល្បុក្កតោ

✻ ដំបងវែងប្រើមេទូកបាក់ វាយចុងមួយ

- កន្សែងប្រើក្បាច់ស្តាយលៀង



- ក្បិនក្រហម វាយដំបង សង្កត់រះលើចំហៀង ដោយប្រើស្នៀតដំបងចុងមួយមេទូកបាក់ ។ មេនេះប្រើឈាវម្តងម្កាលបន្តិច ប៉ុន្តែវាយបកឆ្វេងស្តាំរបៀបចែវច្រវាទូក ។

- ឯខាងក្រមា ប្រើក្បាច់កន្សែងស្តាយលៀង គឺបត់ ក្រមាជាពីរ ស្តាយស្មាម្ខាង ចេញគុនដៃក្បាច់ល្បុក្កតោ រួចឆក់ក្រមា វាយរងទប់ ។ ស្នៀតនេះ ខាងក្រមាប្រើទាំងដៃ ទាំងជើង ធាក់ផង គឺធាក់ចុងដំបងម្ខាង ។

## ✱ ដំបងវែងប្រើបញ្ឆោតមេផាត់ប្រមូល

- កន្សែងប្រើមេឃឹតធ្នូ ទប់ឆ្វេង បំបែកស្ដាំ



- ក្នុងការប្រើកន្សែង ដែលជាលក្ខណៈសាមញ្ញមកទប់នឹងដំបងវែងនេះ មានភាពពិបាកណាស់ ទាល់តែអ្នក ដែលប្រើកន្សែងចេះមេគុនដៃទ្វារប្រាំបីស្ទាត់ ទើបទប់ទល់ដំបងវែងនេះបាន ។

- មេនេះ ដំបងវែងប្រើមេផាត់ប្រមូល វាយលើបុកក្រោម ឯកន្សែង ប្រើមេឃឹតធ្នូ ទប់ដំបង វាយតម្រង់ក្បាល រួចលុតជង្គង់ទម្លាក់កន្សែងចុះ ទប់មេដំបង ឈ្មោះថា "បុកស្នឹង" បុកតម្រង់ជើង ។

- ដំបងវែងប្រើមេរា គឺជាមេដែលពិបាករងទប់ទល់ ព្រោះមេនេះបញ្ឆោត ឆ្វេងស្ដាំ រាមុខរាក្រោយ ជំហានដកមុខ ដកក្រោយបញ្ឆោត ។



- កន្សែងប្រើមេចង្វាយផ្ដៅមូរពីក្នុង ចេញក្រៅ ចូលក្នុង។

- ការប្រកួតនេះឈ្មោះថា "ស្វាដណ្ដើមទី" ដំបងប្រើដៃបុកញាប់ដូចកង្ហារបក់ ឯកន្សែងបង់កបត់ជាពីរ ចេញ មេគុនដៃក្បាច់ចង្វាយផ្ដៅ បញ្ឆោតរៀងខ្លួន វាយដណ្ដើមទីគ្នា គឺឆ្លងខ្សែបន្ទាត់ដណ្ដើមចូលទីម្ខាងម្នាក់ ។ ពេលឈរ លើទីម្នាក់ៗត្រូវទប់ទល់ឱ្យខ្លាំងដោយទប់ក្បាច់រៀងៗខ្លួន ។

## * ដំបងវែងប្រើមេបុកស្នួរ ឬក្រពើវាត់កន្ទុយ



**- កន្សែងប្រើមេព័ទ្ធស្នឹង ព័ទ្ធលើ ដកដំហ៊ានថយក្រោយ ត្រៀមសម្រុករុលចូល ពេលដំបងវាយលើ ។**

- ដំបងវែងបុកតម្រង់ជើងអ្នកគុនកន្សែងទាញទប់ចំកណ្ដាលដំបង ត្រៀមលើកទប់ចុងដំបងដែលបម្រុងវាយពីលើក្បាល មេនេះបុរាណខ្មែរឱ្យឈ្មោះថា "មេព័ទ្ធស្នឹង" ជួនកាលកន្សែងរុលចូលពេលដំបងដកចុះក្រោម ដោយយក ក្រមារុលព័ទ្ធខ្លួនអ្នកវាយដំបង ចងពីក្រោយ ។

## * ដំបងវែងប្រើមេដាវវែង វាយបុកចំហៀងច្រើនប្រើរបៀប បុកចំហៀង វាយចំហៀង ។



**- កន្សែងប្រើមេស៊កទទឹង បំបែកធរណី កាត់ទប់ចងបង្រួញដំបង ដកជើងថយ ពឹងដងខ្លួនផ្ទឹបដំបង ។**

- មេដាវវែងដែលដំបងវែងប្រើនេះ មិនបុកចំពីមុខទេ គឺ បុកតែពីចំហៀង ឆ្វេងស្ដាំ ដែលបុរាណខ្មែរឱ្យឈ្មោះថា "មេដាវវែង" មេនេះមានប្រសិទ្ធភាពណាស់ ចំពោះការប្រកួតដំបងវែងជាមួយក្បាច់ដាវ ឬដំបងខ្លី ។ ឯគុនកន្សែង ក៏ពិបាកទប់នឹងមេនេះដែរ ទាល់តែប្រើមេស៊កទទឹងក្បាច់ ចង-ក ប្រកួតទប់ទាំងកន្សែង ទាំងដងខ្លួន ទើបជាប់ ។

* ដំបងវែងប្រើមេកាត់ត្រឡាច វាយកាត់ឆ្វេងស្តាំ កាត់លើ កាត់ពាក់កណ្តាលខ្លួន



**- កន្សែងប្រើមេទ្វារប្រាំបី ទប់មេបួន**

- មេកាត់ត្រឡាច ឬហនុមាន អូសព្រះខ័ន ដែលដំបងវែងប្រើនេះ គឺវាយបកចំហៀង ត្រឡប់ឆ្វេងស្តាំ បង្វិលខ្លួនជុំវិញ រួចវាយកាត់ចំពាក់កណ្តាលខ្លួន ។

- កន្សែងប្រើមេទ្វារប្រាំបី ប៉ុន្តែកាត់យកទប់បំបែក តែ មេបួន គឺទប់លើ ឆ្វេងស្តាំ ទប់ពាក់កណ្តាលខ្លួនឆ្វេងស្តាំ ប៉ុណ្ណោះ ។

* ដំបងវែងមេឆៀងកណ្តៀត

**- ក្បាច់ដេញស្វា**

**- កន្សែងមេខ្ទាទះ**

**- ក្បាច់លំពង់រាជ្យ**

- ក្បាច់ឆៀងកណ្តៀត ដែលដំបងវែងវាយនេះ គឺវាយពុះចំហៀងពីលើ ដេញពីក្រោយខ្នងឆ្វេងស្តាំ ដែលបុរាណខ្មែរឱ្យឈ្មោះថា "ក្បាច់ដេញស្វា" គឺដេញវាយសត្វស្វាពីក្រោយ ។



- ឯកន្សែងប្រើមេខ្ទាទះ គឺរងពីក្រោយ រួចទាញដំបងទម្លាក់មកខាងមុខ ទាំងឆ្វេងទាំងស្តាំ ដូចគ្នា ។ ក្បាច់នេះខ្លះឱ្យឈ្មោះថា "លំពង់រាជ្យ" គឺរុលមកមុខ ឬរុលថយក្រោយ ។

*** ដំបងវែងមេទូកបាក់**



**- ក្បាច់គោះច្រវ៉ា**

**- កន្សែងមេបកផ្កា ក្បាច់ជ្រងនាគ**

- ដំបងប្រើមេទូកបាក់នេះ គឺបុកផង គាស់ផង របៀបចែវច្រវ៉ាទូក ចុងដំបង ចាក់ចំភ្លៅគូប្រកួត រួចក៏បោះជើងចូលសម្រុកវាយចំហៀងចុងដំបងខាងលើ ទៅលើគូប្រកួតហៅថា "មេទូកបាក់ ឬគោះច្រវ៉ា" ។

- ចំណែកកន្សែងទប់មេបកផ្កា គឺទប់ ហើយបកដៃពីខាងក្រោម បង្វិលខ្លួនគៀសដំបងចេញ ដែលបុរាណខ្មែរឱ្យឈ្មោះថា "មេជ្រងនាគ" ។

*** ដំបងវែងមេបុកច្រាំង**

**ក្បាច់ រាជសីហ៍**

**- កន្សែងមេបំបែកខណ្ឌ**

**- ក្បាច់ក្រុងអង្រុត**



- ដំបងវែងប្រើមេបុកច្រាំង គឺវាយ គៀសលើ បុកក្រោម បញ្ឆោតបុកក្រោម របៀបរាជសីហ៍គៀសកន្ទុយប្រុងលោត ចាប់ចំណី ប្រើរបៀបនេះ សន្ទប់ទៅលើគូប្រកួត ។

* រីឯកន្សែងទប់លើបញ្ឆិត ដែល បុរាណខ្មែរឱ្យឈ្មោះថា មេក្រុងអង្រុត គឺក្រុងដំបងរហូតទាបដល់ដី រើមិនរួច ។

### ✵ ដំបងវែងមេផាត់ប្រមូល ក្បាច់បកចំហៀង ឬស្រទាប់ផ្កា



**- កន្សែងមេត្រកួញព័ទ្ធ**

**- ក្បាច់ក្រញាំឥន្ទ្រី**

- ដំបងវែងវាយរបៀបកៀសចូលក្នុង ត្រឡប់ឆ្វេងស្តាំ ចំពាក់កណ្តាលខ្លួន ហៅថា មេផាត់ប្រមូល ។ ក្បាច់នេះវាយកៀសមូរពីលើចុះក្រោម ដែលហៅថា មេបកចំហៀង ឬមេបកស្រទាប់ផ្កា ។

- ចំណែកកន្សែងប្រើបង្រួញ ក្រមា ដកជើងមុខក្រោយ ចាំស្ទាក់ដំបងពេលដំបងកៀសរកខ្លួន ដែលហៅថា មេបង្រួញព័ទ្ធ ឬក្បាច់ក្រញាំឥន្ទ្រី ។

### ✵ ដំបងវែងមេដោតទង់

**- ក្បាច់គោះព្រលឹង**

**-កន្សែងមេក្រពើហា**

**- ក្បាច់អន្ទាក់ស្វា**



- ដំបងវែងប្រើបុកចុងម្ខាងចុះដី យកកម្លាំងវាយចុងខាងលើ ទៅចំចំណុចក្បាលគូប្រកួត ដែល បុរាណខ្មែរឱ្យឈ្មោះថា " មេដោតទង់ ឬ ក្បាច់គោះព្រលឹង" គឺបុកផាំង វាយផាំង បុកក្រោម វាយលើ ។

- កន្សែងដកជើងដែលដំបងដេញបុក រួចកន្សែងទាញត្រដាង ទប់ចំពីមុខ របៀបក្រពើហាមាត់ ដែលហៅថា "ក្បាច់ក្រពើហា" រួចដកដៃចងដំបងដែលហៅថា "ក្បាច់អន្ទាក់ស្វា" ។

**✻ ដំបងវែងមេបកក្រោយ**



**- ក្បាច់ជំហានដំរី**

**-កន្សែងមេបិទថែប**

**-ក្បាច់ខ្លាអង្គុញកន្ទុយ**

- ដំបងវាយពីមុខ រួចត្រឡប់ខ្លួនបង្វិលវាយពីក្រោយ គឺវាយលើ វាយក្រោម រួចបោះជំហានវែង១ ដែលហៅថា "មេបកក្រោយ ឬ ក្បាច់ជំហានដំរី" ។

- កន្សែងរងរុញទប់ បិទក្បៀរដល់ខ្លួនអ្នកវាយដំបង បន្ទន់ខ្លួន របៀបខ្លាអង្គុញយកកម្លាំងទប់ដំបងដែលឱ្យឈ្មោះថា "មេបិទថែប ក្បាច់ខ្លាអង្គុញកន្ទុយ" ។

**✻ ដំបងវែងមេទប់ទ្រនាប់**



**- ក្បាច់ចោលដឹង**

**-កន្សែងមេចងថ្នក់**

**- ក្បាច់តោង ច្បូតកន្ទុយនាគ**

-មេទប់ទ្រនាប់ គឺដំបងវែងប្រើដំបងចុងមួយ វាយច្បូតដល់គល់ដំបង វាយតែចុងម្ខាងចំកញ្ចឹង-ក ពីចំហៀងឆ្វេងស្តាំដៃគូប្រកួត ដែលឱ្យឈ្មោះថា "មេទប់ទ្រនាប់ ឬ ក្បាច់ចោលដឹង" ។

✻ កន្សែងរងទប់ដៃស្តាំ ឃ្លាតជាងដៃឆ្វេង បើទប់ឆ្វេង ដៃឆ្វេងវែងជាងដៃស្តាំ ដែលឱ្យឈ្មោះថា "មេកន្សែងចងថ្នក់ ឬក្បាច់ច្បូតកន្ទុយនាគ" ។

* ដំបងវែងមេប្ដូរទប់ជង្គង់



- ក្បាច់ថ្វាយព្រះច័ន្ទ
-កន្សែងមេមាន់ក្រុងកូន
-ក្បាច់ស្រងឈាម

- ដំបងវែងប្រើបុកឆ្វេង លោតបុកស្ដាំ រហ័សដូចស្វាប្ដូរទី ប្រើចុងពីរទាំងសងខាងដែលឱ្យឈ្មោះថា "មេប្ដូរទប់ជង្គង់ ឬក្បាច់បន្ទឺភ្លេង ថ្វាយព្រះចន្ទ" ។

-កន្សែងទប់ចុងដំបងជំរុញទាបចុះដី ផ្ទប់ដៃនឹងជង្គង់ យកកម្លាំងសង្កត់ដំបង ទាក់ចុងកុំឱ្យដំបងគ្រលាស់ចេញរួច ហើយបង្វិលខ្លួនចងដំបង ដែលឱ្យឈ្មោះថា "ក្បាច់មេមាន់ក្រុងកូន ឬស្រងឈាម" ។

* ដំបងវែងមេបទស្ទឹង



- ក្បាច់បំបែកក្អម
-កន្សែងមេប្រមោយដំរី
- ក្បាច់ព្រយុងវល្លិ

-ដំបងវែងវាយចុងបង្ហួស រួចគៀសមកវិញ បុកចំក្បាលពីមុខ ដែលហៅថា "មេបទស្ទឹង" ឯគៀសបោះជំហានចូលបុកហៅថា "ក្បាច់បំបែកក្អមទឹក" ។

- កន្សែងប្រឹងទប់កម្លាំងដៃចំពីមុខ ត្រៀមបោះជំហានចូលចងដំបង ដែលហៅថា "មេប្រមោយដំរី ឬក្បាច់ព្រយុងវល្លិ" គឺថ្លក់ចងដំបងពីលើចុះក្រោម ។

**✻ ដំបងវែងមេបកកណ្ដឹងគោ**



- **ក្បាច់រាជសីហ៍បក់កន្ទុយ**

**-កន្ទ្រេងមេក្ងួចប្រមូល**

**-ក្បាច់ចងក្រពើ**

- មេបកកណ្ដឹងគោ គឺដំបងបុកបញ្ឆោត រួចវាយបកចុងខាងលើពីស្ដាំ ដោយបោះជើងស្ដាំចូល ដែលហៅថា "ក្បាច់រាជសីហ៍បក់កន្ទុយ" ។

✻ ឯកន្ទ្រេងទាក់អង្គញចុងដំបង ដែលបុករួចបោះជំហ៊ានចូលធាក់ បំបាក់ជើងឆ្វេងអ្នកកាន់ដំបង ដែលហៅថា "មេក្ងួចប្រមូល ឬក្បាច់ចងក្រពើ" ។

✻ ក្បាច់កែងដៃ (សរព្រះរាម) មាន ១០ របៀប

✻ ភ្លាត់ដៃគងសិរិទ្ធមាន ៨ របៀប



✻ កដៃ ៤ជ្រុង មាន ៤ របៀប

✻ កណ្ដាប់ដៃកំរោល ៤ ជ្រុង មាន ៦ របៀប

✻ ជង្គង់បាក់ភ្នំ ឬ ភ្នំបាក់ មាន ៥ របៀប

✻ ស្ទ័នជើងព្យុះសមុទ្រ មាន ៤របៀប

✻ បាតកែងជើងអង្គត់ខ្មៅ ឬ កងចក្រខ្មៅ មាន ៥ របៀប

* ភ្នែកគោល ភ្នែកគោលក្នុង ភ្នែនឥសី មាន ២ របៀប ភ្នែកគោលក្រៅ ជើងកែង មាន ៤ របៀប
* បាតជើងព្រះរាម  មាន ៣ របៀប
* ក្តិលជើង ជើងខ្មោច មាន ២ របៀប
* ខ្វាំបាតជើង បាតជើងអារក្ស  មាន ២ របៀប
* ស្នូងជើង ជើងទាបសេដា  មាន ៣ របៀប រួមទាំងដៃទាំងជើង  មាន ១០០ មេ នេះនៅក្នុងភាគអាស្ន័ណ ។
* មេអាស្ន័ណយុទ្ធមាន ៨ ទ្វារ  ពីទ្វារ១ ដល់ទ្វារ ៨ មាន ជាង ៣.០០០ ស្នៀត ។
* មេហាណ្ណុយុទ្ធមាន ៦ភាគៈ ១. ដំបងវែង  ២. លំពែង  ៣. ខ្សែតី  ៤. ដំបងវែងចុងមួយ ចុងពីរ ។ល។

